# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលខ្លឹមសារនៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ និងលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងអនុក្រឹត្យលេខ ១៥ ដល់លេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- តាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥

## សម្រេច

**មាត្រា ១ :** កែសំរួលអនុក្រឹត្យលេខ ១៥ ដល់លេខ ៣៨អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដោយលុបចេញ នូវសមាសភាពតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការវិនិយោគកម្ពុជា ដែលជាអនុប្រធានអចិន្ត្រៃយ៍ ។

**មាត្រា ២ :** អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវចាត់តាំង អនុប្រធានអចិន្ត្រៃយ៍ និងជាប្រធានលេខាធិការដ្ឋាន ជំនួសសមាសភាព ដែលបានលុបចេញខាងលើ ។

**មាត្រា ៣ :** ក្រៅពីការកែសំរួលបណ្តាចំណុចខាងលើ ខ្លឹមសារនៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង នៅរក្សាទុកជាធរមានដដែល ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានកន្លងមក ហើយដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ